ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៨_សសរ

# សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតគណៈកម្មការដើម្បីអនុវត្តសេចក្ដីជូនដំណឹង

## លេខ ១០០៤ សជណ.អវ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការមួយដើម្បីអនុវត្តសេចក្ដីជូនដំណឹងលេខ ១០០៤ សជណ.អវ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីអំពីការអនុញ្ញាតជាគោលការណ៍អោយនិស្សិតដែលមានសញ្ញាប័ត្រមកពីជំរុំបានបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

គណៈកម្មការនេះ មានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១_ឯកឧត្តម | សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២_ឯកឧត្តម | ប៉ុក ថន | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៣_ឯកឧត្តម | អ៊ឹម សិទ្ធី | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៤_ឯកឧត្តម | ឡាំ សុខា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |

| | | | |
|---|---|---|---|
| ៥_ឯកឧត្តម | ស៊ាន បូរ៉ាត | ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៦_ឯកឧត្តម | ពេជ សោភ័ន | អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សាបច្ចេកទេស និង វិជ្ជាជីវៈ | សមាជិក |
| ៧_លោក | ខៀវ ថាទិត្យា | ប្រធាននាយកដ្ឋានព័ត៌មាន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨_លោក | ខឹម ទិសិដ្ឋ | ប្រធាននាយកដ្ឋានអប់រំ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩_លោក | តែ្ត សុខា | ប្រធាននាយកដ្ឋានឧត្តមសិក្សា | លេខាធិការ |

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ច ៖

_ពិភាក្សា និង លើកវិធានការត្រួតពិនិត្យផ្ទៀងផ្ទាត់លើសន្លឹកសញ្ញាប័ត្ររបស់និស្សិតដែលមកពីជំរុំអោយបានត្រឹមត្រូវ ។

_ពិនិត្យ និង សំរេចលើសំណើសុំបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សារបស់និស្សិតដែលមានសញ្ញាប័ត្រមកពីជំរុំពិតប្រាកដ ។

_រាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣** : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ប្រធានគណៈកម្មការអាចបង្កើតអនុគណៈកម្មការជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៤** : គណៈកម្មការនេះ ត្រូវរំសាយជាស្វ័យប្រវត្តិនៅពេលបានបំពេញភារកិច្ចចប់ជាស្ថាពរ ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០២*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ_កាលប្បវត្តិ*